

ខុមហ្វ្រែល
COMFRE

# ឃ្លាំមើលសភា និងតំណាងរាស្ត្រ

*របាយការណ៍ឆ្នាំទី៤ លេខ ១៧ នីតិកាលទី៤ខែមករា ដល់មិថុនា ២០១២*

# មាតិកា

**I. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ** ...... 2

១- ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំវិសាមញ្ញ ...... 2

២-ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ ...... 3

**II. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ** ...... 3

*ក្រាហ្វិកទី១៖ ភាគរយកំណើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សចន្លោះពីខែមេសា-មិថុនា ២០១២ធៀបនឹងមករា-មិនា ២០១២* ...... 4

*ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្សក្នុងអំឡុងពេលពី ខែ មករា ដល់ មិនា ២០១២* ...... 5

*ក្រាហ្វិកទី៣៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស ក្នុងអំឡុងពេល ពីខែ មេសា ដល់ មិថុនា ២០១២* ...... 6

*តារាងទី១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សក្នុងអំឡុងពេល មករាដល់មីនា ២០១២* ...... 6

*តារាងទី២៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សក្នុងអំឡុងពេល មេសា ដល់មិថុនា ២០១២* ...... 9

*ក្រាហ្វិកទី៤៖ ភាគរយកំណើនការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងនីមួយៗ ចន្លោះពីខែ មេសា ដល់ មិថុនា ២០១២ ធៀបនឹង ចន្លោះខែ មករា ដល់ មិនា ២០១២* ...... 11

**III. ការចេញលិខិតអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ** ...... 11

**VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ** ...... 12

ការចុះធ្វើអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងតែងតែជួបឧបសគ្គ ...... 12

អ្នកតំណាងរាស្ត្រតែងជួបផលពិបាកក្នុងការទទួលអភ័យឯកសិទ្ធិពីប្រព័ន្ធតុលាការ ...... 13

អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីចោទ នាយករដ្ឋមន្ត្រី និងនីតិប្រតិបត្ត រំលោភរដ្ឋធម្មនុញ្ញ ...... 14

រដ្ឋសភាជាតិក្នុងដើមឆ្នាំនេះ ( មករា ដល់ មិថុនា) ឆ្នាំ២០១២ រដ្ឋសភាមានការប្រជុំចំនួនពីរលើក។ រដ្ឋសភាមានការប្រជុំវិសាមញ្ញចំនួនមួយលើកនៅពេលដែលរដ្ឋសភាវិស្សមកាល និងមានការបើកសម័យប្រជុំពេញអង្គសាមញ្ញចំនួនមួយលើក។

រដ្ឋសភាជាតិក្នុងខែមករា ដល់ខែមិនា ឆ្នាំ២០១២ មានការប្រជុំវិសាមញ្ញមួយលើក គឺជារយៈពេលសម្រាកបន្ទាប់ពីសម័យប្រជុំលើកទី៧ ដែលស្ថិតនៅក្នុងរយៈពេលពីខែតុលា ដល់ខែធ្នូឆ្នាំ២០១១។ ក្នុងរយៈពេលសម្រាកនេះ រដ្ឋសភា មានការប្រជុំវិសាមញ្ញមួយលើក។

រដ្ឋសភាជាតិក្នុងខែមេសា ដល់ខែមិថុនា មានការប្រជុំមួយលើកក្នុងអំឡុងខែមេសាដែលរដ្ឋសភាជាតិបានបើក សម័យប្រជុំពេញអង្គលើកទី៨។ ក្នុងរយៈពេលនេះជាពេលដែលរដ្ឋសភាមមាញឹកក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់។

## I. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ

### ១- ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំវិសាមញ្ញ

រដ្ឋសភាក្នុងអំឡុងខែមីនា មានការប្រជុំវិសាមញ្ញ ១ពេល (ព្រឹក) ដោយរដ្ឋសភាមានរបៀបវារៈចំនួន២ដែលត្រូវអនុម័តទីមួយការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន២រូបដែលមានសំលេងគាំទ្រ(៨២/១០២) និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ (ស្នើពីរដ្ឋាភិបាល)ដោយជាការប្រញាប់ ដែលមានសំលេងអនុម័ត ៨៤/៩៩។

ក្នុងការពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ក្នុងអំឡុងពេលនោះមានតែតំណាងរាស្ត្រ៤រូបមកពីគណបក្សចំនួន២(គណបក្ស សម រង្ស៊ី និងគណបក្សប្រជាជនកម្ពុជា) ក្នុងចំណោមគណបក្សចំនួន៥ដែលមានអាសនៈនៅក្នុងរដ្ឋសភា។ ចំពោះគណបក្សទាំង២នេះបានឡើងបញ្ចេញមតិមានចំនួន៨២នាទី ការបញ្ចេញមតិផ្តោតទៅលើតួអង្គរដ្ឋាភិបាល ការផ្តល់អនុសាសន៍លើសេចក្តីព្រាងច្បាប់កំពុងពិភាក្សាលើរបៀបវារៈ មណ្ឌលខ្លួនឯង/ដ៏ទៃទៀត និងតួអង្គតំណាងរាស្ត្រដ៏ទៃទៀត។

ជាមធ្យមអ្នកតំណាងរាស្ត្រ១រូបបញ្ចេញមតិបាន២០នាទី ព្រោះថាភាគច្រើនប្រធានក្រុមនៃអ្នកតំណាងរាស្ត្របានឡើងបញ្ចេញមតិពិភាក្សាច្រើនជាងគេ។

ចំណែកខ្លឹមសារនៃការបញ្ចេញមតិរបស់តួអង្គខាងលើ គឺមានលក្ខណៈអព្យាក្រឹតចំនួន៤១នាទី(ស្មើនឹង៥០%នៃការបញ្ចេញមតិសរុប)ខ្លឹមសារវិជ្ជមាន ឬសរសើរដល់តួអង្គខាងលើមានចំនួន៦នាទី (ស្មើនឹង៧%) និងខ្លឹមសារអវិជ្ជមាន ឬរិះគន់មានចំនួន៣៥ (ស្មើនឹង៤៣%)។

អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានគាំទ្រលើសេចក្តីព្រាង/ស្នើច្បាប់ ដែលរាជរដ្ឋាភិបាលស្នើនោះបានឡើងបញ្ចេញមតិ២រូបចំនួន៣ដងស្មើនឹង២៥នាទី។ ការបញ្ចេញមតិភាគច្រើនរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សនេះគឺលើកពីការងាររបស់រាជរដ្ឋាភិបាលដែលបានធ្វើកន្លងមក។

ចំណែកអ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានឡើងបញ្ចេញមតិចំនួន២រូប និងបានបញ្ចេញមតិចំនួន៣ដងដែលស្មើនឹង៥៧នាទី។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សនេះ ផ្តោតលើការលើកឡើងលើការរិះគន់ជជែកពីចំនុចខ្វះខាតរបស់សេចក្តីព្រាងច្បាប់ ការផ្តល់អនុសាសន៍ និងសុំស្នើដល់រាជរដ្ឋាភិបាលដែលជាអ្នកការពារសេចក្តីព្រាងច្បាប់ រួមទាំងបញ្ហាប្រឈមផ្សេងៗរបស់មណ្ឌល។

ក្នុងការប្រជុំវិសាមញ្ញរដ្ឋសភាមានការប្រកាសផ្លាស់ប្តូរអ្នកតំណាងរាស្ត្រចំនួន៦រូប មកពីគណបក្សប្រជាជនកម្ពុជាចំនួន១រូប និងគណបក្សសមរង្ស៊ីចំនួន៥រូប នៅក្នុងការប្រជុំវិសាមញ្ញនេះរួមមានការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន២រូប សម្តេចព្រះរៀម នរោត្តម បុប្ផាទេវី និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័នមុនីរក្ស ដោយមានសំលេង៨២/១០២។

## ២-ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ

រដ្ឋសភាជាតិបានបើកសម័យប្រជុំពេញអង្គសាមញ្ញលើកទី៨ក្នុងរយៈពេល១ព្រឹក( មេសា ដល់មិថុនា)។ ការបើកសម័យប្រជុំពេញអង្គនេះ រដ្ឋសភាមានរបៀបវារៈចំនួន៣ សុទ្ធតែការបោះឆ្នោតជ្រើសតាំងសមាជិកក្នុងរដ្ឋសភា។ ក្នុងរយៈពេលនេះ រដ្ឋសភាមិនមានការពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់/សេចក្តីស្នើច្បាប់ក្នុងអំឡុងពេលដែលរដ្ឋសភាចូលវិស្សមកាលនោះទេ។

រដ្ឋសភាសភាមានរបៀបវារៈចំនួន៣ ក្នុងពេលបើកសម័យប្រជុំពេញអង្គសាមញ្ញលើកទី៨ របៀបវារៈទីមួយ ការបោះឆ្នោតជ្រើសតាំងលោកជំទាវ ឃួន សុដារី ជាអនុប្រធានទី២នៃរដ្ឋសភា ត្រូវបានសមាជិក សមាជិកានៃរដ្ឋសភាបានបោះឆ្នោតអោយមានសំលេង ៨៣/១០១។ ក្នុងការបោះឆ្នោតនេះក៏មានសំលេង យល់ព្រម៨៣សំលេង មិនព្រមចំនួន ១៧សំលេង និងអនុប្បវាទ ១សំលេង។ ក្នុងរបៀបវារៈទីពីរ ការបោះឆ្នោតជ្រើសតាំងឯកឧត្តម ពៅ សាមី ជាសមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា ត្រូវបានសមាជិក សមាជិកានៃរដ្ឋសភាបោះឆ្នោតបានសំលេង ៨២/១០១ និងការជ្រើសតាំងលោកជំទាវ អ៊ុន សុគន្ធា ជាសមាជិកាគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ ត្រូវបានសមាជិក សមាជិកានៃរដ្ឋសភាបានបោះឆ្នោតអោយបានសំលេង ៨១/១០១។

ចំពោះរបៀបវារៈទីបី ការជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ ចំនួន១រូបត្រូវបានសមាជិករដ្ឋសភា បានបោះឆ្នោតជ្រើលរើស ឯកឧត្តម ប្រាក់ ចំរើន ជាសមាជិកព្រឹទ្ធសភានីតិកាលទី៣ ដែលមានសំលេង ៩៨/១០១។

ក្នុងដើមឆ្នាំនេះ ការបើកសម័យប្រជុំពេញអង្គសាមញ្ញរបស់រដ្ឋសភាលើកទី៨ មិនមានការប្រជុំពិភាក្សា លើសេចក្តីព្រាងច្បាប់ឬក៏សេចក្តីស្នើច្បាប់នោះទេដោយមានការបោះឆ្នោតជ្រើសតាំងតែមួយលើកតែប៉ុណ្ណោះ។ ការប្រជុំរបស់រដ្ឋសភាមានការថយចុះជាងសម័យប្រជុំពេញអង្គសាមញ្ញលើកទី៧ ដែលមានការកោះប្រជុំពិភាក្សាចំនួន ៦ដងទៅ៧ដង។

តាមការសង្កេតរបស់ខុមហ្វ្រែលបានឃើញថា ក្នុងឆ្នាំនេះជាឆ្នាំដែលមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ដែលធ្វើអោយអ្នកតំណាងរាស្ត្រគ្រប់គណបក្សនីមួយៗដែលមានសមាជិកក្នុងរដ្ឋសភាមានការមមាញឹកក្នុងការចុះមូលដ្ឋានច្រើន។ មិនថាតែអ្នកតំណាងរាស្ត្រទេដែលចុះមូលដ្ឋានឃើញថា មន្ត្រីក្នុងជួររដ្ឋាភិបាលក៏មានការចុះមូលដ្ឋានច្រើនផងដែរដែលជាកត្តាធ្វើឲ្យការប្រជុំពេញអង្គលើកទី៨របស់រដ្ឋសភា មានការថយចុះជាង៧៥% (ស្មើនឹង១លើកធៀបនឹងសម័យប្រជុំពេញអង្គលើក៧របស់រដ្ឋសភាប្រជុំបាន៤លើក) ក្នុងការប្រជុំពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់/ សេចក្តីស្នើច្បាប់របស់រាជរដ្ឋាភិបាល។

## II. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

តាមទិន្នន័យខុមហ្វ្រែលដែលទទួលបានពីគណបក្សនយោបាយ ការិយាល័យតំណាងរាស្ត្រ និងពីប្រពន្ធ័ផ្សព្វផ្សាយបានបង្ហាញឲ្យឃើញថា ក្នុងរយៈពេល៦ខែនេះ(មករា ដល់មិថុនា២០១២) មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន៩២រូប ស្មើនឹង៧៥%នៃចំនួនអ្នកតំណាងរាស្ត្រសរុបក្នុងរដ្ឋសភា(១២៣រូប) បានចុះមូលដ្ឋានសរុប ១៣៩១លើក។

ក្នុងអំឡុងពីពេលដើមឆ្នាំ (មករាដល់មីនា) មានអ្នកតំណាងរាស្រ្ត ៧១រូប ស្មើនឹង៥៨% នៃចំនួនអ្នកតំណាងរាស្រ្តសរុប (១២៣រូប) បានចុះមូលដ្ឋានសរុប៦៦០លើក។ ក្នុងរយៈពេល៣ខែចុងក្រោយនេះ (មេសាដល់មិថុនា) មានអ្នកតំណាងរាស្រ្ត ៦៩រូបស្មើនឹង៥៦%នៃចំនួនអ្នកតំណាងរាស្រ្តសរុប(១២៣រូប) បានចុះមូលដ្ឋានសរុប៧៣១លើក។

**រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ៖**

គណបក្ស ប្រជាជនកម្ពុជា

គណបក្ស សមរង្ស៊ី

គណបក្ស សិទ្ធិមនុស្ស

គណបក្ស ហ៊្វុនស៊ិនប៉ិច

គណបក្ស នរោត្តមរណឫទ្ធិ

បើតាមការសង្កេតរបស់ខុមហ្វ្រែល បើគិតពីចំនួនអ្នកតំណាងរាស្រ្ត ដែលបានចុះមូលដ្ឋានក្នុងរយៈពេល៣ខែនេះ(មេសាដល់មិថុនា)ចំនួនអ្នកតំណាងរាស្រ្តដែលបានចុះមូលដ្ឋានមានការថយចុះជាង២៣%នៃចំនួនអ្នកតំណាងរាស្រ្តដែលបានចុះមូលដ្ឋានក្នុងរយៈពេល៣ខែមុន(មករាដល់មិនា)ដែលមាន៧១រូប។ ប៉ុន្តែបើគិតជាចំនួនការចុះមូលដ្ឋាន របស់អ្នកតំណាងរាស្រ្តក្នុងខែ (មេសាដល់មិថុនា) មានការកើនឡើង ៥%នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្តក្នុងរយៈពេល៣ខែមុន(មករាដល់មីនា) ដែលមានអ្នកតំណាងរាស្រ្តបានចុះ៦៦០លើក។

ក៏ប៉ុន្តែចំពោះរបាយការណ៍ក្នុងអំឡុង៦ខែនេះ(មករាដល់មិថុនា) ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្តនៅក្នុងមណ្ឌលចំនួន៣មណ្ឌល គឺមណ្ឌលរតនៈគីរី មណ្ឌលកោះកុង និងមណ្ឌលកែប ។

ក្នុងរយៈពេល៣ខែនេះ (មេសា ដល់ មិថុនា) ដែលជាពេលដែលជិតដល់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលធ្វើអោយអ្នកតំណាងរាស្រ្តបង្កើនការចុះមូលដ្ឋានរបស់ខ្លួនក្នុងស្វែងរកសន្លឹកឆ្នោត ដែលជាកត្តាធ្វើអោយការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្តមានការកើនឡើងជាងមុន( មករា ដល់ មិនា) ។

ប៉ុន្តែ ចំនួនអ្នកតំណាងរាស្រ្តគណបក្ស ហ៊្វុនស៊ិនប៉ិច និងតំណាងរាស្រ្តគណបក្សសមរង្ស៊ី បែរជាមានការថយចុះ ក្នុងអំឡុងពេលបោះឆ្នោតនេះ អ្នកតំណាងរាស្រ្តគណបក្ស សម រង្ស៊ី និងតំណាងរាស្រ្ត គណបក្សហ៊្វុនស៊ិនប៉ិច មានការមមាញឹកក្នុងការឃោសនាបោះឆ្នោតដែលមិនបានបង្ហាញក្នុងរបាយការណ៍នេះ។

***ក្រាហ្វិកទី១៖ ភាគរយកំណើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្តតាមគណបក្សចន្លោះពីខែមេសា-មិថុនា ២០១២ ធៀបនឹងមករា-មិនា ២០១២***




បើគិតពីចំនួនចុះមូលដ្ឋានរបស់តំណាងរាស្រ្តឃើញថា តំណាងរាស្រ្តគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្រ្តគណបក្សសិទ្ធិមនុស្សបានចុះមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមតំណាងរាស្រ្តទាំង៥គណបក្ស នៅក្នុងរដ្ឋសភា។

ចំពោះតំណាងរាស្រ្តគណបក្សសិទ្ធិមនុស្ស ៣រូប បានចុះមូលដ្ឋាន សរុប ១៨០លើក គឺមានការកើនឡើងជាង

មុន៧១% ធៀបនឹង៣ខែមុន( មករា ដល់ មិនា) ចុះបាន១០៥លើក។ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មានការកើនឡើង១៣% ដែលក្នុងរយៈពេល៣ខែនេះ(មេសា ដល់មិថុនា) ចុះបាន៤៤៥លើក ដែលធៀបនឹងរយៈពេល៣ខែមុន(មករាដល់មិនា) ចុះមូលដ្ឋានបាន៣៩១លើក។

តំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ បានបន្តការចុះមូលដ្ឋានមានការកើនឡើង៥០% ដោយក្នុងរយៈពេល៣ខែ នេះ(មេសាដល់មិថុនា) បានចុះមូលដ្ឋានចំនួន៦លើក បើធៀបនឹង៣ខែមុន(មករាដល់មីនា) ចុះមូលដ្ឋានបាន៣លើក។

ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី មានការថយចុះ ២៦% ក្នុងរយៈពេល៣ខែនេះ (មេសាដល់មិថុនា) អ្នកតំណាងរាស្ត្រចុះបាន១០០លើក ធៀបនឹងរយៈពេល៣ខែមុន(មករាដល់មិនា) ចុះមូលដ្ឋាន បាន១៣៥លើក។

ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច មានការថយចុះ១០០% ដោយក្នុង៣ខែនេះ អ្នកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចមិនមានសកម្មភាពចុះមូលដ្ឋានទេ បើធៀបនឹងរយៈពេល៣ខែមុនចុះមូលដ្ឋានបាន២៦លើក។

បើគិតក្នុងអំឡុងពេល៣ខែ(មករាដល់មិនា) អ្នកតំណាងរាស្ត្រជាមធ្យមក្នុងម្នាក់ចុះមូលដ្ឋានឃើញថា តំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្សបានចុះច្រើនជាងគេ ដោយតំណាងរាស្ត្រមួយរូប ចុះបាន៣៥លើក។ តំណាងរាស្ត្រគណបក្ស ប្រជាជនកម្ពុជាជាមធ្យមចុះបាន ៧លើក តំណាងរាស្ត្រគណបក្សសមរង្ស៊ីជាមធ្យមចុះបាន១១លើក តំណាងរាស្ត្រគណបក្ស នរោត្តមរណឫទ្ធិជាមធ្យមចុះបាន៣លើក និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចជាមធ្យមចុះបាន១៣លើក។

ចំពោះក្នុងពេល៣ខែនេះ(មេសាដល់មិថុនា) គិតជាមធ្យមនៃតំណាងរាស្ត្រម្នាក់ៗដែលចុះមូលដ្ឋានតាមគណបក្ស ឃើញថាតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សនៅតែចុះច្រើនជាងគេដដែល គិតជាមធ្យមចុះបាន៦០លើក តំណាងរាស្ត្រ គណបក្សសមរង្ស៊ីគិតជាមធ្យមចុះបាន១៤លើក តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាមធ្យមចុះបាន៨លើក និងតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិជាមធ្យមចុះបាន៦លើក។ ចំណែកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ ក្នុងអំឡុង៣ខែនេះមិនមានសកម្មភាពក្នុងការចុះមូលដ្ឋានទេ។

គួរអោយកត់សំគាល់ថា ជាធម្មតាជិតដល់បោះឆ្នោតគ្រប់គណបក្សតែងតែបង្កើនសកម្មភាពចុះមូលដ្ឋាន តែផ្ទុយទៅវិញសកម្មភាពចុះមូលដ្ឋានរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច មានការថយចុះដោយក្នុងអំឡុងពេលបោះឆ្នោតបែរជាមិនមានសកម្មភាពចុះមូលដ្ឋានទៅវិញ។

***<u>ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្សក្នុងអំឡុងពេលពីខែ មករា ដល់ មិនា ២០១២</u>***




ភាគរយនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបនឹងភាគរយនៃអាសនៈសភាសរុបតាមគណបក្សបានបង្ហាញថា ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដែលមានអាសនៈប្រមាណ៣%បានចុះមូលដ្ឋានបានប្រមាណ១៦%ស្មើនឹង៥ដងនៃចំនួនអាសនៈសរុបរបស់គណបក្សនេះ។ ចំណែកអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ដែលមានប្រមាណអាសនៈ២១%នៅក្នុងរដ្ឋសភា បានចុះមូលដ្ឋានប្រមាណ២១%សមាមាត្រស្មើនឹងចំនួនអាសនៈសរុបរបស់គណបក្សនេះ។ តំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច គឺស្ទើរតែសមាមាត្រទៅនឹងអាសនៈរដ្ឋសភាដែលគណបក្សនីមួយៗទទួលបានក្នុងរដ្ឋសភា ដែល

រួមគ្នាមានអាសនៈប្រមាណ៣%ក្នុងរដ្ឋសភាក៏ចុះមូលដ្ឋានបាន៤%ដែរ។ ចំពោះតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលមានអាសនៈ ៧១%នៅក្នុងរដ្ឋសភាចុះមូលដ្ឋានបានតែ ៥៩%នៃការចុះមូលដ្ឋានសរុបដែលចំនួននេះ គឺស្មើនឹងជាងពាក់កណ្តាលនៃចំនួនអាសនៈរបស់គណបក្សនេះក្នុងរដ្ឋសភាប៉ុណ្ណោះ។

***<u>ក្រាហ្វិកទី៣៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្សក្នុងអំឡុងពេលពីខែ មេសា ដល់ មិថុនា ២០១២</u>***




ភាគរយការចុះមូលដ្ឋានរបស់តំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្សក្នុងអំឡុងពេល៣ខែ (មេសាដល់មិថុនា) ឃើញថា

តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមានអាសនៈ៣% នៅក្នុងសភាចុះមូលដ្ឋានបាន ២៤% ស្មើនឹង៨ដងនៃអាសនៈគណបក្សខ្លួន។

តំណាងរាស្ត្រគណបក្សសមរង្ស៊ី ដែលមានអាសនៈ ២១% ចុះមូលដ្ឋានបាន១៤% នៃការចុះមូលដ្ឋានសរុប គឺ ស្មើនឹងជាងពាក់កណ្តាលនៃចំនួនអាសនៈរបស់គណបក្សនេះក្នុងរដ្ឋសភា។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ គឺស្មើរតែសមាមាត្រទៅនឹងអាសនៈរដ្ឋសភាដែលគណបក្សនីមួយៗទទួលបានក្នុងរដ្ឋសភាដែលរួមគ្នាមានអាសនៈ១.៥%ក្នុងរដ្ឋសភាក៏ចុះមូលដ្ឋានបាន១%ដែរ។ ចំពោះតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលមានអាសនៈ ៧៣% នៅក្នុងរដ្ឋសភា ចុះមូលដ្ឋានបាន៦១%នៃការចុះមូលដ្ឋានសរុប។

***<u>តារាងទី១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សក្នុងអំឡុងពេល មករាដល់មីនា ២០១២</u>***

| **គោលបំណងនៃការចុះមូលដ្ឋានទាំង៦៦០លើករបស់តំណាងរាស្ត្រទាំង ៧១រូប** | **គណបក្សនយោបាយ** | | | | | សរុបគោលបំណង |
|---|---|---|---|---|---|---|
| | ៥៣រូប | ២រូប | ១២ រូប | ៣ រូប | ១ រូប | |
| សាកសួរសុខទុក្ខចែកអំណោយនិងការសម្ពោធសមិទ្ធផលនានា | ២២៥ (៥៧%) | ៦ (២៣%) | ៣១ (២៣%) | ៦៩ (៦៦%) | 0 | ៣៣១ (៥0%) |
| ការចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្ស | ៩៨ (២៥%) | ១៩ (៧៣%) | ៩៩ (៧៤%) | ៣៥ (៣៣%) | ២ (៦៧%) | ២៥៣ (៣៨%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ៦៤ (១៦%) | ១ (៣%) | 0 | 0 | ១ (៣៣%) | ៦៦ (១0%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ២ (១%) | 0 | ៣ (២%) | ១ (១%) | 0 | ៦ (១%) |
| ការអន្តរាគមន៍និងដោះស្រាយបញ្ហានានា | ២ | 0 | ២ | 0 | 0 | ៤ |

| | | | | | | |
|---|---|---|---|---|---|---|
| | (១%) | | (១%) | | | (១%) |
| **សរុបគោលបំណងតាមគណបក្ស** | **៣៩១** | **២៦** | **១៣៥** | **១០៥** | **៣** | **៦៦០ (១០០%)** |

តារាងទី១បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រ គឺផ្តោតទៅលើគោលបំណងសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់៣៣១លើក (ឬ៥០%នៃការចុះមូលដ្ឋានសរុប) ដែលមានការកើនឡើងជាងរយៈពេល៣ខែមុន។ ការចុះអមដំណើរថ្នាក់ដឹកនាំ ៦៦លើក(១០% នៃការចុះមូលដ្ឋានសរុប) ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន២៥៣លើក (៣៨%នៃការចុះមូលដ្ឋានសរុប)។ ដោយឡែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានតិចតួចប៉ុណ្ណោះសរុបបាន៦លើក (១%នៃការចុះមូលដ្ឋានសរុប)។ ចំណែកការចុះអន្តរាគមន៍និងការដោះស្រាយបញ្ហានានាជួយប្រជាពលរដ្ឋវិញនៅតែមានតិចតួចនៅឡើយ គឺត្រឹម៤លើកស្មើនឹង១%នៃការចុះមូលដ្ឋានសរុប ដែលចំនួននេះមានការកើនឡើងជាងរយៈពេល ៣ខែមុន។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៥៣រូប ចុះបានសរុប៣៩១លើក)៖** ជាសរុបតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានច្រើនជាងគណបក្សផ្សេងៗ។ ក្នុងនោះ៥៧%នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺក្នុងគោលបំណងសួរសុខទុក្ខចែកអំណាយ និងសម្ពោធសមិទ្ធផលនានា(២២៥លើក)ការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ស្មើ១%(២លើក) និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន ១៦%(៦៤លើក)។

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាក៏បានចុះមូលដ្ឋាន ក្នុងគោលបំណងពង្រឹងគណបក្សរបស់ខ្លួនដែលសរុបមាន២៥%(៨៨លើក)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈមាន១% (២លើក)។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖**

អ្នកតំណាងរាស្ត្រ **ជួញ សុផៃ**មកពីមណ្ឌលបាត់ដំបង កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១២ បានអញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំមេភូមិ ប្រជាពលរដ្ឋសរុបចំនួន៥៥៥នាក់ នៅសាលាឃុំបឹងព្រីង ស្រុកថ្មគោល និងឧបត្ថម្ភម្នាក់ៗ ថវិកាចំនួន១០០០០ រៀល។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ្ស៊ិនស៊ិនប៊ិច (២រូប ចុះបានសរុប ២៦លើក)៖** ជាសរុបតំណាងរាស្ត្រគណបក្សហ្ស៊ិនស៊ិនប៊ិចបានចុះមូលដ្ឋានចំនួន២៦លើក ក្នុងនោះ៧៣%នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សហ្ស៊ិនស៊ិនប៊ិចគឺក្នុងគោលបំណងពង្រឹងគណបក្សរបស់ខ្លួនដែលសរុបមាន១៩លើក។ ចំណែកក្នុងគោលបំណងសួរសុខទុក្ខចែកអំណោយនិងសម្ពោធសមិទ្ធផលនានាបាន២៣%(៦លើក) និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ១០% (១លើក)។

ចំពោះការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា សិក្ខាសាលាសាធារណៈ និងការចុះអន្តរាគមន៍ដោះស្រាយបញ្ហានានា ខាងគណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋាននេះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សហ្ស៊ិនស៊ិនប៊ិចមានដូចជា៖**

អ្នកតំណាងរាស្ត្រ**ញឹក ប៊ុនឆៃ** នៅមណ្ឌលបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១២ បានអញ្ជើញចុះទៅឃុំតាឡំ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ សំរបសំរួលការធ្វើផ្លូវលំបន្តពីភូមិបឹងវែងមកភូមិបឹងឃ្លាំងមានប្រវែង៤០០ម៉ែត្រ។ មានអ្នកចូលរួម៥០០នាក់ចែកអាវម្នាក់១ ថវិកា១ម៉ឺនរៀល ថ្នាំ១ប្រអប់។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី (១២រូប ចុះសរុបបាន១៣៥លើក)៖** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានសួរសុខទុក្ខ(២៣% ឬ៣១លើកនៃការចុះមូលដ្ឋានរបស់គណបក្សនេះសរុប) ការពង្រឹងបណ្តាញគណបក្ស (ស្មើនឹង៧៤% ឬ៩៩លើក) និងការចូលរួមវេទិកាសាធារណៈ(ស្មើនឹង២%ឬ៣លើក) និងការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ស្មើ១%(២លើក)។ ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំខាងគណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋាននេះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានដូចជា៖**

អ្នកតំណាងរាស្ត្រ **យន្ត ថារូ** នៅមណ្ឌលបន្ទាយមានជ័យ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ បានអញ្ជើញចុះនៅឃុំសំបូរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ក្នុងគោលបំណង អញ្ជើញចុះមកអន្តរាគមន៍ការបាត់បង់ដីធ្លីបងប្អូនប្រជាកសិករដែលបានបាត់បង់ដីស្រែអស់៧០០ហិចតាជាង ដោយសារខាងក្រសួងធនធានទឹក ក្រសួងកសិកម្មដកយកដាក់ជាសម្បត្តិរដ្ឋ។ ឯកឧត្តមក៏មានការសន្យាថានឹងទទួលយករឿងទាំងអស់នេះទៅដោះស្រាយនៅរដ្ឋសភា និងព្រឹទ្ធសភា ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស (៣រូប ចុះបានសរុប១០៥លើក)៖**ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើចុះសួរសុខទុក្ខ ដែលមានដល់ទៅ៦៦%(៦៩លើក) នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ។ ការចុះពង្រឹងគណបក្សមាន៣៣% (៣៥លើក) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ១% (១លើក)

គណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមានដូចជា៖**

អ្នកតំណាងរាស្ត្រ **គឹម សុខា** មកពីមណ្ឌលកំពង់ចាម បាននាំមុខគេក្នុងការចុះមូលដ្ឋានក្នុងចំណោមតំណាងរាស្ត្របានចុះមូលដ្ឋាន និងក្នុងបក្សរបស់ខ្លួនបានចុះចំនួន៤៨ដង។ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ អញ្ជើញចូលរួមប្រជុំនៅឃុំជើងភ្នំស្រុកបាភ្នំខេត្តព្រៃវែង គោលបំណងសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមានភ្ញៀវចូលរួមប្រហែល១០០នាក់ ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ (១រូប ចុះបាន៣លើក)៖** ខុមហ្វ្រែលទទួលបានព័ត៌មានតែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុប៣លើក(នៃការចុះមូលដ្ឋានសរុប)។ ក្នុងគោលបំណងចុះពង្រឹងគណបក្សមាន៦៧%(២លើក) និងអមដំណើរថ្នាក់ដឹកនាំ៣៣%(១លើក)។ ក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ សាកសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធផល និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនគណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិនោះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិមានដូចជា៖**

អ្នកតំណាងរាស្ត្រ **សៅ រ៉ានី** មកពីមណ្ឌលព្រៃវែង កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១២ អញ្ជើញចុះអមដំណើរយាងរបស់សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិចុះមកជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋអ្នកគាំទ្រនៅក្នុងស្រុកបរិបូណ៌ខេត្តកំពង់ឆ្នាំង។

***តារាងទី២៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សក្នុងអំឡុងពេល មេសា ដល់មិថុនា ២០១២***

| **គោលបំណងនៃការចុះមូលដ្ឋានទាំង៧៣១លើករបស់តំណាងរាស្ត្រទាំង៦៩រូប** | **គណបក្សនយោបាយ** | | | | សរុបគោលបំណង |
|---|---|---|---|---|---|
| | **៥៨រូប** | **៧ រូប** | **៣ រូប** | **១ រូប** | |
| សាកសួរសុខទុក្ខចែកអំណោយនិងការសម្តោធសមិទ្ធផលនានា | ៣០១ (៦៨%) | ៦៨ (៦៨%) | ១២៥ (៦៩%) | 6 (១០០%) | ៥០០(៦៨%) |
| ការចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្ស | ១១៣ (២៥%) | ៣១ (៣១%) | ៥៤ (៣០%) | 0 | ១៩៨ (២៧%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ២៩ (៦%) | 0 | 0 | 0 | ២៩ (៣%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | 0 | ១ (១%) | ១ (១%) | 0 | ២ (១%) |
| ការអន្តរាគមន៍និងដោះស្រាយបញ្ហានានា | ២ (១%) | 0 | 0 | 0 | ២ (១%) |
| **សរុបគោលបំណងតាមគណបក្ស** | **៤៤៥** | **១០០** | **១៨០** | **៦** | **៧៣១ (១០០%)** |

តារាងទី២បានបង្ហាញថា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រភាគច្រើនផ្តោតទៅលើគោលបំណងសាកសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលការចុះមានរហូតដល់ ៥០០លើក(ស្មើនឹង៦៨%នៃការចុះមូលដ្ឋានសរុប)។ ចំណែកក្នុងគោលលំដាប់ទីពីរ ដែលអ្នកតំណាងរាស្ត្របានផ្តោតទៅលើការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សរបស់ខ្លួនបាន១៩៨លើក (ស្មើនឹង២៧% នៃចំនួនចុះមូលដ្ឋានសរុប)។ ចំពោះក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំបានត្រឹម ២៩លើក (ស្មើនឹង៣%នៃចំនួនចុះមូលដ្ឋានសរុប)។ ដោយឡែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានតិចតួចប៉ុណ្ណោះសរុបបាន២លើក (១%នៃការចុះមូលដ្ឋានសរុប)។ ចំណែកការចុះអន្តរាគមន៍ និងការដោះស្រាយបញ្ហានានាជួយប្រជាពលរដ្ឋវិញនៅតែមានតិចតួចនៅឡើយ គឺត្រឹម២លើកស្មើនឹង១%នៃការចុះមូលដ្ឋានសរុប។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៥៨រូប ចុះបានសរុប៤៤៥លើក)៖** ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាភាគច្រើនផ្តោតលើការចុះសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា បាន ៦៨% (ស្មើនឹង៣០១ដង)នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស ១១៣ដង( ស្មើនឹង២៥%)។ ចំណែកការចុះដ្ឋានក្នុងគោលបំណង អមដំណើរថ្នាក់នាំ ២៩ដល់ (ស្មើនឹង ៦%) និងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា ២ដង (ស្មើនឹង១%)នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ចំពោះក្នុងគោលបំណងចូលរួមវេទិកាសាធារណៈ ខាងខុមហ្វ្រែលមិនបានទទួលព័ត៌មានទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖**

អ្នកតំណារាស្ត្រ **ប៉ាល់ សំអឿន** មណ្ឌលបន្ទាយមានជ័យ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ បានអញ្ជើញចុះសំណេះសំណាលសួរសុខទុក្ខនៅបរិវេណវត្តប្រាសាទខ្វារលិច ដែលមានអ្នកចូលរួមសរុបចំនួន៣៩៩នាក់ ក្នុងនោះបានចែក

អំណោយម្នាក់ៗ ប៊ីចេង ១ថង់ នំប៉័ង ទឹកសុទ្ធ ចំណែកអ្នកឆ្លើយសំណួរ៤នាក់ ម្នាក់ៗទទួលបានថវិកា ១០០០០រៀល ស្ថិតនៅឃុំ រលួសស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី(៧រូប ចុះបានសរុប១០០លើក)៖**ការចុះមូលដ្ឋានរបស់គណបក្សនេះបានផ្តោតទៅលើការចុះសួរសុខទុក្ខ និងសំណេះសំណេះប្រជាពលរដ្ឋបាន ៦៨លើ(ស្មើនឹង៦៨%)នៃការចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្ស ៣១លើក (ស្មើនឹង៣១%) និងការចុះមូលដ្ឋានក្នុងគោលបំណងចុះចូលរួមវេទិកាសិក្ខាសាលាសាធារណៈបានត្រឹម១លើក ស្មើនឹង១%នៃការចុះមូលដ្ឋានសរុបរបស់បក្សខ្លួន។ ចំណែក្នុងគោលបំណង ចុះអមដំណើរថ្នាក់នាំគណបក្សខ្លួន និងគោលបំណងអន្តរាគមន៍និងដោះស្រាយបញ្ហានានា ខាងខុមហ្វ្រែលមិនបានទទួលព័ត៌មាននោះទេ ដែលអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានដូចជា៖**

អ្នកតំណាងរាស្ត្រ **សុវណ្ណា ពិសាខា** មណ្ឌលកំពង់ចាម បានចុះមូលដ្ឋានបាន(៦៤លើក)ច្រើនជាគេក្នុងចំណោមអ្នកតំណាងរាស្ត្រគណបក្សរបស់ខ្លួន ។ កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១២បានអញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលក្នុងនោះមានអ្នកចូលរួម២៨៥នាក់ ស្រុកថ្មគោល ខេត្តបាត់ដំបង។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស (៣រូប ចុះបានសរុប១៨០លើក)៖** ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើចុះសួរសុខទុក្ខ ដែលមានដល់ទៅ៦៩%(១២៥លើក) នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ។ ការចុះពង្រឹងគណបក្សមាន៣០% (៥៤លើក) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ១% (១លើក)។

គណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមានដូចជា៖**

អ្នកតំណាងរាស្ត្រ គឹម សុខា មណ្ឌលកំពង់ចាម បានចុះមូលដ្ឋាននាំមុខគេក្នុងចំណោមអ្នកតំណាងរាស្ត្រគណបក្សខ្លួនចុះបាន ៩៤លើក ។ កាលពីថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១២ បានអញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមានអ្នកចូលរួម៣៣០នាក់ ស្ថិតនៅក្នុងស្រុក ពញាក្រែក ខេត្តកំពង់ចាម។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ (១រូប ចុះបាន៦លើក)៖** ការចុះមូលដ្ឋានរបស់គណបក្សនេះខាងខុមហ្វ្រែលទទួលបានការចុះសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតែមួយប៉ុណ្ណោះ ៦លើក(ស្មើនឹង១០០%) ចំពោះក្នុងគោលបំណងចំនួន ៤ទៀត ដូចជា ការចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្ស ការចុះអមដំណើរថ្នាក់ដឹកនាំ ការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានា និងគោលបំណងចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈ ខាងខុមហ្វ្រែលមិនបានទទួលព័ត៌មានដែលពាក់ព័ន្ធនឹងអ្នកតំណាងរាស្ត្រចុះមូលដ្ឋាននោះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ មានដូចជា៖**

អ្នកតំណាងរាស្ត្រ **យូ ហុកគ្រី** មណ្ឌលកំពង់ចាម ចុះមូលដ្ឋានបាន៦លើក។ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ **យូ ហុកគ្រី**បានអញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ។

***ក្រាហ្វិកទី៤៖ ភាគរយកំណើនការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងនីមួយៗ ចន្លោះពីខែ មេសា ដល់ មិថុនា ២០១២ ធៀបនឹង ចន្លោះខែ មករា ដល់ មិនា ២០១២***




ភាគរយកំណើនការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក្នុងគោលបំណងនីមួយៗ ចន្លោះពីខែមេសាដល់មិថុនា ធៀបនិងចន្លោះខែ(មករាដល់មិនា) ខុមហ្វ្រែលបានឃើញថា ការចុះមូលដ្ឋាន របស់តំណាងរាស្ត្រ ក្នុងគោលទាំងប្រាំគោលបំណង ដែលអ្នកតំណាងរាស្ត្រចុះ ឃើញថាមានតែមួយគោលបំណងទេដែលមានការកើនឡើង ចំណែកក្នុងគោលបំណងបួនទៀតឃើញថា មានការថយចុះជាងរយៈពេល៣ខែមុន។ ក្នុងបំណងចុះសួរសុខទុក្ខចែកអំណោយ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋមានការកើនឡើង៥១% (៥០០លើក) ធៀបនឹងរយៈពេល៣ខែមុន( មករា ដល់មិនា) ចុះបាន៣៣១លើកនៃការចុះមូលដ្ឋានក្នុងគោលបំណងនេះ។ ក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញបក្ស យើងឃើញថាក្នុងរយៈពេល៣ខែនេះ មានការថយចុះ២១% (ស្មើនឹង១៩៨លើក)នៃអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន ធៀបនឹងការចុះមូលដ្ឋានក្នុងរយៈពេល៣ខែមុនចុះបាន២៥៣លើក។ ចំណែកក្នុងគោលបំណង ចុះអមដំណើរថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ឬក៏ថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនមានការថយចុះ៥៦% បើធៀបនឹងការចុះមូលដ្ឋានក្នុងអំពេល៣ខែមុន ដែលចុះបាន៦៦លើក។ ចំពោះការចុះក្នុងគោលបំណងវេទិកាសាធារណៈ និងសិក្ខាសាលាមានការថយចុះ៦៦% បើធៀបនឹងរយៈពេល៣ខែមុន ចុះបាន៦លើក។ ការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានការថយចុះជាងរយៈពេល៣ខែមុន៥០% (ដែលចុះបាន២លើក) ធៀបនឹង៣ខែមុនចុះបាន៦លើក។

## III. ការចេញលិខិតអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ

ក្នុងអំឡុងដើមឆ្នាំនេះ(មករា ដល់ មិថុនា ) ខុមហ្វ្រែលបានសង្កេតឃើញថា មានអ្នកតំណាងរាស្ត្រ ៣រូប ក្នុងចំណោម ២គណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា បានចេញលិខិតអន្តរាគមន៍សរុបចំនួន៩ច្បាប់ដាក់ជូនទៅរាជរដ្ឋាភិបាល។

ក្នុងចំណោមតំណាងរាស្ត្រ៣រូប មានតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន២រូប និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមាន១រូប ដែលបានដាក់លិខិតទៅរាជរដ្ឋាភិបាល។ ក្នុងនោះ តំណាងរាស្ត្រគណបក្សសមរង្ស៊ី ២រូប បានចេញលិខិតចំនួន៥ច្បាប់ ដែលលិខិតទាំងនោះសុទ្ធតែជាលិខិតស្នើទៅរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានានាដូចជាៈទីមួយ ការស្នើប្រមុខរាជរដ្ឋាភិបាលអញ្ជើញមកឆ្លើយបំភ្លឺដោយផ្ទាល់មាត់នៅមន្ទីររដ្ឋសភាលើការងារបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ទីពីរ ការស្នើទៅរដ្ឋាភិបាលកុំអោយអនុញ្ញាតឲ្យកសាងតំបន់វារីអគ្គិសនីនៅ "អារ៉ែង" និងសុំមានវិធានការបញ្ឈប់ការកាប់ឈើអានាធិបតេយ្យនៅតំបន់ទំនប់វារីអគ្គិសនី តាតៃ ក្នុងស្រុកថ្មបាំង ខេត្តកោះកុង។ ទីបី ស្នើសុំចាត់វិធានការបន្ទាន់បំផុតមួយ ដើម្បីធ្វើអោយដំឡូងមីរបស់ប្រជាកសិករខ្មែរមានតម្លៃឡើងវិញ និងទីបួន មានការស្នើ

សេចក្តីព្រាងច្បាប់ស្តីពី " សេរីភាពក្នុងការទទួលព័ត៌មាន"។ល។ និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចេញលិខិតជូនរដ្ឋាភិបាលចំនួន ៤ច្បាប់។

នៅក្នុងរយៈពេល៣ខែ( មករា ដល់មិនា) ឃើញថា មានអ្នកតំណាងរាស្ត្របានចេញលិខិតចំនួន ៨ច្បាប់ដាក់ទៅរាជរដ្ឋាភិបាល។ ចំណែករយៈពេល៣ខែក្រោយនេះ (មេសាដល់ មិថុនា) ឃើញមានតំណារាស្ត្រ១រូបបានដាក់លិខិតចំនួន១ច្បាប់ដាក់ទៅរាជរដ្ឋាភិបាល។

ការដាក់លិខិតរបស់អ្នកតំណាងរាស្ត្រទាំង៩លិខិតនេះ ទៅរាជរដ្ឋាភិបាលសុទ្ធតែជាលិខិតស្នើ និងអំពាវនាវដល់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានានា ។

ក្នុងការសង្កេតនេះ ខុមហ្វ្រែលទទួលបានថា លិខិតដែលអ្នកតំណាងរាស្ត្រដាក់ទៅជូនរាជរដ្ឋាភិបាល មិនទាន់ឃើញមានការឆ្លើយតបពីសំណាក់រាជរដ្ឋាភិបាលទេ។

## VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### ការចុះធ្វើអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងតែងតែជួបឧបសគ្គ

ការប្រើប្រាស់យន្តការតុលាការក្នុងការគាបសង្កត់អ្នកតំណាងរាស្ត្រមកពីគណបក្សមិនកាន់អំណាច នឹងនាំឲ្យតួនាទីស្ថាប័នសភាក្នុងការឃ្លាំមើលរាជរដ្ឋាភិបាល និងភាពជាតំណាងរាស្ត្រក្នុងការការពារផលប្រយោជន៍ដល់ម្ចាស់ឆ្នោតកាន់តែខ្សោយថែមទៀត ។

នៅដើមឆ្នាំ២០១២នេះ (មករាដល់មីនា) មានព្រឹត្តិការណ៍សំខាន់ៗ ដែលបានកើតឡើងលើអ្នកតំណាងរាស្ត្រ និងអាចមានឥទ្ធិពលអវិជ្ជមានក្នុងការបំពេញតួនាទីរបស់អ្នកតំណាងរាស្ត្រ។ មានអ្នកតំណាងរាស្ត្រគណបក្សប្រឆាំង១រូប ត្រូវបានរងការប្តឹងទៅតុលាការពីបទបានរំដោះអ្នកភូមិបុរីកីឡា ១៨នាក់ ក្នុងនោះមានកុមារ ៤នាក់ផង ចេញពីការឃុំឃាំង។ ចំពោះអ្នកតំណាងរាស្ត្រនៃគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ការចុះអន្តរាគមន៍តែងតែជួយឧបសគ្គដោយមានការគំរាមកំហែងពីសំណាក់អាជ្ញាធរ។ ជាក់ស្តែង លោកជំទាវ មូរ សុខហួរ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី បានមានប្រសាសន៍ថា "*កាលហ្នឹងព្រះរាជអាជ្ញា ថាមែន(មានគេប្តឹង) ប៉ុន្តែមិនមានចំណាត់ការ ប៉ុន្តែព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹងមែន ហើយមិនមានការចាត់ការទេ*"។

ការប្តឹងអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងរូបនេះ ទៅតុលាការដោយគ្រាន់តែ ចុះសំណេះសំណាល និងធ្វើអន្តរាគមន៍អោយប្រជាពលរដ្ឋដែលជាតួនាទីរបស់អ្នកតំណាងរាស្ត្រ បែរជាត្រូវអាជ្ញាធរប្តឹងទៅវិញ នេះជាហេតុធ្វើអោយអ្នកតំណាងរាស្ត្រមិនអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញ។

លោកជំទាវ មូរ សុខហួរអ្នកតំណាងរាស្ត្រមណ្ឌលកំពតរបស់ គណបក្សសម រង្ស៊ី ត្រូវបានប្រធានមណ្ឌលសង្គមកិច្ចព្រៃស្ពឺបានប្តឹង ដោយមានហេតុផលថា «*តាមគោលការណ៍ បើលោកស្រីមូរ សុខហួរ មិនមែនជាសាច់ញាតិរបស់ពលរដ្ឋទាំងនោះទេ គឺត្រូវសុំការអនុញ្ញាត និងផ្តល់ព័ត៌មានជាមុន ទើបអាចអនុញ្ញាតឱ្យចូលទៅក្នុងមណ្ឌលបាន ។ នៅពេលនោះពលរដ្ឋទាំង១៨នាក់ឃើញលោកស្រី មូរ សុខហួរ ទៅដល់ក៏ចាប់ផ្តើមជ្រួលច្របល់ធ្វើឱ្យបាត់សណ្តាប់ធ្នាប់*»។

ការបំពេញភារកិច្ចជាអ្នកតំណាងរាស្ត្រតែងតែជួបឧបសគ្គប៉ះពាល់ដល់ខ្លួនឯង នៅពេលដែលបំពេញតួនាទី។ នេះហើយជាហេតុធ្វើអោយអ្នកតំណាងរាស្ត្រដែលតំណាងអោយរាស្ត្រទាំងមូលមានផលវិបាក និងមានការស្ទាក់ស្ទើរក្នុងការចុះ

បំពេញតួនាទី និងភារកិច្ចជាអ្នកតំណាងរាស្ត្រ។ អ្នកតំណាងរាស្ត្រ **មូរ សុខហួរ**មានប្រសាសន៍ថា៖ *«ខ្ញុំបំពេញភារកិច្ចកាតព្វកិច្ចរបស់ខ្ញុំ តាមសម្បជញ្ញៈរបស់ខ្ញុំ តាមអ្វីដែលខ្ញុំយល់ឃើញថា ជាកាតព្វកិច្ចនៃអ្នកតំណាងរាស្ត្រទៅពន្យល់ ទៅជួយរាស្ត្រ។ បើសិនជាការដែលខ្ញុំបកស្រាយអំពីច្បាប់ ទៅជាការបរិហារកេរ្តិ៍ ការដែលខ្ញុំជួយរាស្ត្រដើម្បីឲ្យចេញពីការឃុំឃាំងទៅជាការខុសនឹងច្បាប់ ខ្ញុំសូមយកច្បាប់មកមើលមើល៍។ អ្វីដែលខ្ញុំយល់ឃើញថា ជាការអាម៉ាស់បំផុតនោះ បើសិនជាអ្នកតំណាងរាស្ត្រគិតតែពីជាប់ទោសរបៀបនេះ គឺស្ថាប័នសភាជាអ្នកត្រូវប្រឈមមុខនឹងការអាម៉ាស់មុខនេះ។ តើតម្លៃនៃអ្នកតំណាងរាស្ត្រនៅឯណា? តើស្ថាប័នសភា១ឆ្នាំចាយរាប់លានដុល្លារដើម្បីអី»។*

បច្ចុប្បន្ននេះអ្នកស្រី មូរ សុខហួរ មិនទាន់ទទួលបានអភ័យឯកសិទ្ធិតំណាងរាស្ត្រទេ។ សមត្ថកិច្ចអាចចាប់ខ្លួនអ្នកស្រីបានដោយមិនចាំបាច់ស្នើសុំដកអភ័យឯកសិទ្ធិ។

ចំពោះអ្នកតំណាងរាស្ត្រ ចាន់ ចេង មកពីមណ្ឌលកណ្ដាលគណបក្សសម រង្ស៊ី ត្រូវបានចៅក្រមស៊ើបសួររបស់តុលាការសាលាដំបូងខេត្តកណ្ដាល ប្ដឹងចោទប្រកាន់ពីបទផ្ដល់មធ្យោបាយ និងសម្រួលឲ្យពិរុទ្ធជនដែលជាសកម្មជន[1]គណបក្សសមរង្ស៊ី រត់គេចខ្លួនចេញពីពន្ធនាគារខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១។

ជាលទ្ធផលនៅក្នុងខែមីនា អ្នកតំណាងរាស្ត្រ ចាន់ ចេង ត្រូវបានតុលាការកោះហៅអោយចូលខ្លួនមកបំភ្លឺនៅតុលាការសាលាដំបូងខេត្តកណ្ដាលក្នុងករណីដែលឯកឧត្តម ចាន់ ចេង បានផ្ដល់មធ្យោបាយ និងសម្រួលឲ្យពិរុទ្ធជនបានគេចខ្លួនចេញពីពន្ធនាគារ។ ខណៈពេលអ្នកតំណាងរាស្ត្រ ចាន់ ចេង មកបំភ្លឺនៅតុលាការ ត្រូវបានចៅក្រមសម្រេចមិនឃុំខ្លួនតំណាងរាស្ត្រ ចាន់ ចេង ទេ ដោយចៅក្រមស៊ើបអង្កេតបានដាក់លក្ខខណ្ឌចំនួន៣ ទីមួយ គឺមិនឲ្យចេញទៅក្រៅប្រទេស ទីពី បើមានការផ្លាស់ប្ដូរអាស័យដ្ឋានត្រូវរាយការណ៍មកតុលាការ និងទីបី ត្រូវតែបង្ហាញខ្លួននៅពេលដែលមានការកោះហៅសាជាថ្មីទៀត។ ក្នុងការចុះធ្វើអន្តរាគមន៍ និងការចុះជួយប្រជាពលរដ្ឋរបស់តំណាងរាស្ត្រគណបក្សប្រឆាំងតែងតែជួបឧបសគ្គក្នុងការប្ដឹងផ្ដល់ពីសំណាក់អាជ្ញាធរជានិច្ច។

## អ្នកតំណាងរាស្ត្រតែងជួបផលពិបាកក្នុងការទទួលអភ័យឯកសិទ្ធិពីប្រព័ន្ធតុលាការ

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ**មកពីមណ្ឌលកំពតគណបក្ស សម រង្ស៊ី ត្រូវបានរដ្ឋសភាដកអភ័យឯកសិទ្ធិ កាលពីពាក់កណ្ដាល ខែមេសា ឆ្នាំ២០០៩ នៅពេលលោកស្រី មានរឿងប្ដឹងផ្ដល់ជាមួយ សម្ដេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ នៅថ្ងៃទី១៧ មករា ២០១២ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមកពីមណ្ឌលកំពត លោកស្រី មូរ សុខហួរ បានដាក់ឯកសារពាក់ព័ន្ធនានា ទៅកាន់សាលាដំបូងរាជធានីភ្នំពេញសុំឲ្យតុលាផ្ដល់នូវនីតិសម្បទា ដើម្បីទទួលអភ័យឯកសិទ្ធិជាអ្នកតំណាងរាស្ត្រមកវិញ។ប៉ុន្តែក្នុងករណីសុំនីតិសម្បទានេះ ត្រូវបានតុលាការក្រុងភ្នំពេញបានបដិសេធមិនព្រមទទួលយកលិខិតស្នើសុំរបស់អ្នកតំណាងរាស្ត្រ មូរ សុខហួរ ។

លោក **សុខ រឿន**ព្រះរាជអាជ្ញារងនៃតុលាការក្រុងភ្នំពេញបាននិយាយថា ពាក្យស្នើសុំពុំមានឯកសារគ្រប់គ្រាន់ទេទើបតុលាការសម្រេចមិនទទួលយក។ លោកសុខរឿន បន្តទៀតថា *«ក្នុងពាក្យសុំហ្នឹង គាត់ដាក់មានយោងហើយនិងមានឯកសារពាក់ព័ន្ធ ហើយដល់អញ្ចឹងខាងរដ្ឋបាលគាត់ថា លិខិតដែលដាក់នោះ* មានឯកសារយោងនិងមានឯកសារពាក់ព័ន្ធហ្នឹងតែវាឥត

---

[1] សមាជិកក្រុមប្រឹក្សាឃុំបន្ទាយដែកខេត្តកណ្ដាលរងការចោទប្រកាន់ពីបទបង្កអំពើហឹង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ហើយត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលឃុំខ្លួនដោយពុំបានបង្ហាញដីការឃុំខ្លួន ហើយត្រូវបានមេធាវីការពារក្ដីលោក ជួង ជូងី សំរេចនាំខ្លួនកូនក្ដីត្រឡប់ទៅផ្ទះវិញដោយសារពុំមានដីការឃុំខ្លួន ដោយស្នើឲ្យអ្នកតំណាងរាស្ត្រ ចាន់ ចេង ជួយដឹកត្រឡប់មកផ្ទះវិញ ។

*ឃើញ ។ មន្ត្រីដែលកាន់មកហ្នឹងថា ឥតបានដាក់មក អញ្ចឹងគេសុំយកបណ្ដឹងហ្នឹងសុំទៅវិញ ដើម្បីប្រមូលឯកសារយោងពាក់ព័ន្ធនិងលិខិតពាក្យសុំហ្នឹងណា*»។

អ្នកតំណាងរាស្ត្រ **មួរ សុខហួរ** នៅមិនទាន់បានអភ័យឯកសិទ្ធិពីរដ្ឋសភានៅឡើយទេ មកដល់ពេលនេះ ដោយរដ្ឋសភាមិនទាន់ទទួលលិខិតពីតុលាការ ក្នុងការឲ្យរដ្ឋសភាផ្ដល់អភ័យឯកសិទ្ធិ ។

ចំណែកអ្នកតំណាងរាស្ត្រ **ជាម យៀប** មណ្ឌលព្រៃវែងមកពីគណបក្សប្រជាជនកម្ពុជាមានប្រសាសន៍ថា «*តាមកន្លងទៅយើងឃើញថា បើគេអនុវត្តហើយ ហើយគេស្នើសុំ ដូចនេះតុលាការគួរតែជម្រាបប្រាប់មករដ្ឋសភាវិញ ដើម្បីឲ្យសភាហ្នឹងបានដឹងថា គេអនុវត្ត ហើយគេមាននីតិសម្បទាគ្រប់គ្រាន់ឡើងវិញ* »។

## **អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីចោទ នាយករដ្ឋមន្ត្រី និងនីតិប្រតិបត្តិ រំលោភរដ្ឋធម្មនុញ្ញ**

ក្នុងអំឡុងពេល៦ខែនេះ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានចោទប្រកាន់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រោះគេចមិនចូលខ្លួនមកឆ្លើយបំភ្លឺចំពោះមុខរដ្ឋសភា។ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ក៏បានចោទប្រកាន់ទៅលើប្រធានរដ្ឋសភា ថាមិនបានបញ្ជូនសំណួរសមាជិកសភារបស់ខ្លួនដែលស្នើកោះហៅនាយករដ្ឋមន្ត្រី និងនីតិប្រតិបត្តិ ទៅឆ្លើយបំភ្លឺក្នុងរដ្ឋសភា។

អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញ គណបក្សសមរង្ស៊ី បានចោទប្រកាន់ នាយករដ្ឋមន្ត្រី ថាបានរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដោយមូលហេតុមិនចូលខ្លួនមកបំភ្លឺនៅក្នុងរដ្ឋសភា។ អ្នកតំណាងរាស្ត្រ សុន ឆ័យ បានដាក់លិខិតជាផ្លូវការទៅប្រមុខរាជរដ្ឋាភិបាល ស្នើសុំអោយមកបំភ្លឺពន្យល់ពីកិច្ចប្រជុំអាស៊ាន វិនាសកម្មព្រៃឈើនិងបញ្ហាផ្សេងៗទៀតដែលមានកើតឡើងក្នុងប្រទេសកម្ពុជា។

អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញ គណបក្សសមរង្ស៊ី បានមានប្រសាសន៏ថា « *តួនាទីរបស់រដ្ឋាភិបាលគឺត្រូវតែមកឆ្លើយចំពោះសំណួររបស់អ្នកតំណាងរាស្ត្រ ហើយពេលអ្នកតំណាងរាស្ត្រហៅមកឆ្លើយនៅសភាត្រូវមកឆ្លើយ ហើយមាត្រា៩៦ ដែលបានចែងហ្នឹង ហើយឥឡូវហ្នឹង យើងហៅគាត់ៗអត់មក ហើយយើងសួរសំណួរគាត់ ក៏គេមិនឆ្លើយ អាហ្នឹងគឺរំលោភរដ្ឋធម្មនុញ្ញ* »។

បើតាមការសម្ភាសរបស់វិទ្យុអាស៊ីសេរីទៅអ្នកតំណាងរាស្ត្រ សុន ឆ័យ បានអោយដឹងថាក្នុងអំឡុងឆ្នាំ២០១១ ក្នុងចំណោមលិខិត ឬសំណើរបស់សមាជិកបក្សប្រឆាំងដែលបានស្នើឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយបំភ្លឺលើបញ្ហាជាតិធំៗជាង ១៥០ករណី ដែលមានការឆ្លើយបំភ្លឺមិនបាន ៥០ភាគរយផង ជាពិសេសការឆ្លើយតបមានការយឺតយ៉ាវមិនស្របតាមរដ្ឋធម្មនុញ្ញនោះទេ។

អ្នកតំណាងរាស្ត្រ ជាម យៀប មណ្ឌលព្រៃវែង គណបក្សប្រជាជនកម្ពុជា បានប្រសាសន៍ថា « *តាមច្បាប់រដ្ឋធម្មនុញ្ញបានចែងថា តំណាងរាស្ត្រដាក់សំណួរទៅរដ្ឋាភិបាល ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈ ប្រធានរដ្ឋសភា ហើយតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសសេរជាលាយលក្ខណ៍អក្សរ នៅពេលដែលនាយករដ្ឋមន្ត្រីមានការមមាញឹក និងជាប់រវល់អាចពន្យារពេលក្នុងការឆ្លើយតប ហើយអ្វីដែលលោក សុន ឆ័យ លើកឡើងនោះ គឺវប្បធម៌របស់គណបក្សឆាំង ដែលតែងតែប្រឆាំងនឹងរដ្ឋាភិបាល*»។

ចំណែកលោក ផៃ ស៊ីផាន រដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យទីស្ដីការគណៈរដ្ឋមន្ត្រី បានឆ្លើយតបក្នុងវិទ្យុអាស៊ីសេរីថា ប្រមុខដឹកនាំរដ្ឋាភិបាលសព្វថ្ងៃមិនធ្វេសប្រហែសចំពោះលិខិត ឬសំណើបក្សប្រឆាំងទេ។ លោកបន្តថា មានសំណើមន្ត្រីបក្សប្រឆាំងជាង ៩០ភាគរយ ត្រូវបានប្រមុខដឹកនាំបកស្រាយក្នុងអាណត្តិទី៤ នៃរដ្ឋសភា។

តាមមាត្រា ៩៦ នៃច្បាប់រដ្ឋធម្មនុញ្ញ បានចែងថា « តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា »។

ប្រសិនបើមើលក្នុង ប្រកា ៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា បានចែងថា « ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។» ក្នុង ប្រការ ៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា បានកំណត់ទៀតថា « ចម្លើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំណួរ »។

ជាមួយគ្នានេះដែរ អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញ បានបន្តទៀតថា លោកនឹងចាប់វិធានការប្តឹងទៅ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញដែលជានីតិវិធីសភា និងទៅព្រះមហាក្សត្រ ព្រោះជាគោលការណ៍រាជរដ្ឋាភិបាលក៏ត្រូវជួបព្រះមហាក្សត្រពីរអាទិត្យម្តង ដើម្បីរាយការណ៍ ស្នើឲ្យព្រះមហាក្សត្ររំលឹករដ្ឋាភិបាលត្រូវតែគោរពរដ្ឋធម្មនុញ្ញ ត្រូវឆ្លើយរាល់សំណួរអ្នកតំណាងរាស្ត្រ ហើយនឹងចូលឆ្លើយផ្ទាល់មាត់នៅក្នុងរដ្ឋសភាតាមការកំណត់តាមរដ្ឋធម្មនុញ្ញ។

តាមការសង្កេតរបស់ខុមហ្វ្រែល តាំងពីដើមអាណត្តិរដ្ឋសភានីតិកាលនេះ នាយករដ្ឋមន្ត្រីមិនបានចូលឆ្លើយផ្ទាល់មាត់ទៅសំណួររបស់អ្នកតំណាងរាស្ត្រនៅក្នុងរដ្ឋសភានៅឡើយ។

************************************

ទិន្នន័យការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានប្រមូលមកពី៖ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនីមួយៗ សាខាគណបក្សជាប់ឆ្នោតនីមួយៗនៅតាមខេត្ត គេហទំព័រ (website) របស់គណបក្ស ប្រព័ន្ធផ្សព្វផ្សាយ និងរបាយការណ៍ផ្ទាល់របស់អ្នកតំណាងរាស្ត្រ។ អ្នកតំណាងរាស្ត្រអាចផ្តល់ព័ត៌មានពីការចុះមូលដ្ឋានរបស់ខ្លួនតាមអាស័យដ្ឋានដូចខាងក្រោម៖

ខុមហ្វ្រែល
COMFRE

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា**

ផ្ទះលេខ១៣៨ ផ្លូវ១២២ ទឹកល្អក់១ទួលគោកភ្នំពេញប្រអប់សំបុត្រលេខ១១៩៥
ទូរស័ព្ទ ០២៣៨៨៤១៥០/០១២៩៤២០១៩ ទូរសារ ០២៣៨៨៥៧៤៥
អ៊ីម៉េល៖ Comfrel@online.com.kh គេហទំព័រ៖ www.Comfrel.org